# Mental Health Terms

| Term | English Definition | Khmer Translation/Description |
|---|---|---|
| Aggressive<br>ឆេវឆាវ | Tending toward unprovoked offensives, attacks or invasions | ដែលមានទំនោរប្រមាថមើលងាយគេ វាយប្រហារ ឬឈ្លានពានដោយកំហឹង។ |
| Anxiety<br>ការព្រួយបារម្ភ | A state of apprehension and psychic tension; distress or uneasiness of mind caused by fear of danger or misfortune | សភាពនៃការបារម្ភ និងការតានតឹងក្នុងអារម្មណ៍ ។ ទុក្ខព្រួយ ឬភាពមិនស្រណុកស្រួលផ្លូវចិត្ត ដោយសារខ្លាចមានគ្រោះថ្នាក់ ឬជួបអកុសល ។ |
| Attitude<br>ឥរិយាបទ | Manner, disposition, feeling, position with regard to person or thing; tendency of the mind | ឬកពារ ចរិត អារម្មណ៍ គោលជំហ៊ រ ទាក់ទងនឹងមនុស្ស ឬវត្ថុ និន្នាការរបស់ចិត្ត។ |
| Balance<br>តុល្យភាព | Mental steadiness or emotional stability; habit of calm behavior, judgment | ភាពនឹងនរផ្លូវចិត្តឬសតិអារម្មណ៍ ។ ទម្លាប់មានអាកប្បកិរិយា ស្ងប់ស្ងាត់ សុភវិនិច្ឆ័យ ។ |
| Bipolar<br>ជម្ងឺផ្លូវចិត្ត | Major affective disorder that is characterized by episodes of mania and depression | វិបត្តិផ្លូវអារម្មណ៍យ៉ាងធ្ងន់ធ្ងរដោយសារការស្រមើស្រមៃ និងការកើតទុក្ខក្រៀមក្រំ។ |
| Blame<br>ស្តីបន្ទោស | To hold responsible find fault with; to place the responsibility for | ឲ្យទទួលខុសត្រូវចំពោះកំហុស ។ ដាក់កំហុស ។ |
| Borderline Personality<br>បុគ្គលិកលក្ខណៈ ស្ទើគ្រប់គ្រងមិនបាន | A personality disorder characterized by instability in many areas, as mood, identity, self=image, and behavior, and often manifested by impulsive actions, suicide attempts, inappropriate anger, or depression | វិបត្តិបុគ្គលិកលក្ខណៈដែលកើតឡើងដោយសារភាពមិននឹងនរ ឬអស្ថេរភាព នៅក្នុងរូបភាពជាច្រើន ដូចជា នៅក្នុងអារម្មណ៍ អំពីអត្តសញ្ញាណ អំពីការយល់ឃើញរបស់ខ្លួនឯងនិងអាកប្បកិរិយា និង ជារឿយៗស្តែងចេញតាមរយៈសកម្មភាពដែលមិនបានគិតទុកជាមុន ការប៉ុនប៉ងធ្វើអត្តឃាត កំហឹងផ្តេសផ្តាស់ ឬការខូចចិត្ត។ |
| Coping<br>ការដោះស្រាយ | To deal successfully with or handle a situation; manage | ដោះស្រាយដោយជោគជ័យជាមួយនឹងស្ថានភាពណាមួយ។ ទប់ទល់នឹងស្ថានការបាន ។ |
| Crying<br>យំ | To sob or shed tears because of grief, sorrow, or pain; weep | យំខ្សឹកខ្សួល ឬសម្រក់ទឹកភ្នែក ដោយសារកង្វល់ ការមិនសប្បាយចិត្ត ឬការឈឺចាប់ ។ ទ្រហោរយំ ។ |
| Cultural shock<br>ការមិនស៊ាំនឹងវប្បធម៌ដទៃ | A condition of confusion and anxiety affecting a person suddenly exposed to an alien culture | ស្ថានភាពច្របូកច្របល់ និងការព្រួយបារម្ភ ដែលជះឥទ្ធិពលដល់មនុស្សម្នាក់ភ្លាមៗ ដែលជួបប្រទះនឹងវប្បធម៌ចម្លែក ឬមិនដែលធ្លាប់ជួបប្រទះ ។ |

| Term | English Definition | Khmer Translation/Description |
|---|---|---|
| Delusion<br>សេចក្ដីភាន់នៃវិញ្ញាណ ឬគំនិត | A false belief or opinion | ជំនឿ ឬគំនិតដែលមានការយល់ច្រឡំ ។ |
| Depression<br>ការកើតទុក្ខក្រៀមក្រំ (ការខូចចិត្ត) | The condition of feeling sad or despondent; A psychiatric disorder characterized by an inability to concentrate, insomnia, loss of appetite, feelings of extreme sadness, guilt, helplessness and hopelessness, and thoughts of death. | ស្ថានភាពនៃអារម្មណ៍ក្រៀមក្រំ ឬខូចចិត្ត ។ ជម្ងឺវិកលចរិកកើតឡើងដោយសារអសមត្ថភាពក្នុងការផ្ដោតអារម្មណ៍ ការគេងមិនលក់ ធុំអាហារ អារម្មណ៍ក្ដុកក្ដួលខ្លាំង កំហុស អារម្មណ៍អស់ទីពុំនាក់ និងអស់សង្ឃឹម និងការគិតចង់ស្លាប់។ |
| Insomnia<br>ការគេងពុំលក់ | Chronic inability to fall asleep or remain asleep for an adequate length of time | ការមិនអាចគេងលក់រ៉ាំរ៉ៃសម្រាប់រយៈពេលសមល្មម។ |
| Dissociative Identity<br>អត្តសញ្ញាណមិនចុះសម្រុងជាមួយគេឯង | A condition in which a person displays multiple distinct identities or personalities | ស្ថានភាពដែលមនុស្សម្នាក់បង្ហាញអំពីអត្តសញ្ញាណ ឬបុគ្គលិកលក្ខណៈខុសៗគ្នាពីគេជាច្រើន។ |
| Emotion<br>ការរំជួលចិត្ត | Any strong feeling, as of joy, sorrow, or fear | អារម្មណ៍ដិតណាមួយ ដូចជាអារម្មណ៍សប្បាយរំភើប ទុក្ខព្រួយឬភ័យខ្លាច។ |
| Emotional Exhaustion<br>ការអស់កម្លាំងផ្នែកអារម្មណ៍ | Chronic state of physical and emotional depletion that results from excessive job demands and continuous stress | សភាពរ៉ាំរ៉ៃនៃការចុះខ្សោយផ្នែកសតិអារម្មណ៍ និងរាងកាយ ដែលបណ្ដាលមកពីការទាមទារការងារលើសកម្រិត និងជម្ងឺតានតឹងអារម្មណ៍ជាបន្តបន្ទាប់។ |
| Empowerment<br>ការលើកទឹកចិត្ត | Increasing the spiritual, political, social, or economic strength of individuals and communities | ភាពខ្លាំងខាងផ្នែកស្មារតី នយោបាយ សង្គម ឬសេដ្ឋកិច្ច របស់បុគ្គល និងសហគមន៍។ |
| Energy<br>កម្លាំងចិត្ត | The capacity for work or vigorous activity | សមត្ថភាពធ្វើការងារ ឬសមត្ថភាពសំដែងចេញសកម្មភាពស្វាហាប់ណាមួយ។ |
| Failure<br>បរាជ័យ | The state or condition of not meeting a desirable or intended objective, and may be viewed as the opposite of success | សភាព ឬស្ថានភាពនៃការមិនសម្រេចអ្វីមួយដូចបំណង ឬការមិនសម្រេចគោលដៅណាមួយ អាចជាភាពផ្ទុយគ្នានឹងភាពជោគជ័យ។ |
| Fatigue<br>ការអស់កម្លាំង | Weariness from bodily or mental exertion; physical or mental exhaustion due to exertion | ការអស់កម្លាំងដោយសារការខិតខំប្រឹងផ្លូវរាងកាយ និងផ្លូវចិត្ត។ |
| Fear driven<br>ជម្រុញឲ្យមានភាពភ័យខ្លាច | Something that causes feelings of dread or apprehension; something a person is afraid of | អ្វីមួយដែលបណ្ដាលឲ្យមានអារម្មណ៍ភ័យខ្លាច ឬបារម្ភ ។ អ្វីមួយដែលមនុស្សខ្លាច ។ |

| Term | English Definition | Khmer Translation/Description |
|---|---|---|
| Fearful and worry<br>ភ័យខ្លាច និងបារម្ភ | A cause of uneasiness or anxiety | ការបណ្ដាលមកពីភាពមិនស្រណុកស្រួល ឬក្ដីកង្វល់។ |
| Rejection<br>ការបដិសេធ | The act of rejecting or the state of being rejected | អំពើនៃការបដិសេធ ឬសភាពនៃការដែលត្រូវគេបដិសេធ។ |
| Feeling tense<br>អារម្មណ៍តានតឹង | In a state of mental nervous strain; strain upon the nerves or feelings | នៅក្នុងសភាពនៃសម្ពាធសរសៃប្រសាទខួរក្បាល សម្ពាធទៅលើសរសៃប្រសាទ ឬ អារម្មណ៍។ |
| Flashback<br>ការនឹកឃើញរឿងអតីតកាល | Survivors of traumatic experiences are revisited by elements of the traumatic experience | អ្នកដែលគេចផុតពីការឈឺចាប់ណាមួយ ត្រូវបានធ្វើឲ្យនឹកឃើញឡើងវិញ ដោយផ្នែកណាមួយនៃបទពិសោធន៍ឈឺចាប់នោះ។ |
| Grief<br>ទុក្ខព្រួយ | Keen mental suffering or distress over affliction or loss; sharp sorrow; painful regret | ការឈឺចាប់ផ្លូវចិត្តដោយតក់ក្រហល់ ឬទុក្ខព្រួយដោយសារការឈឺចាប់។ ឬការបាត់បង់អ្វីមួយ។សោកសង្រេងក្រៃលេង ការសោកស្ដាយដ៏ឈឺចាប់ |
| Guilt<br>កំហុស | Remorse or self-reproach caused by feeling that one is responsible for a wrong or offence; the fact or state of having done wrong or committed an offence | វិប្បដិសារី ឬការស្ដីបន្ទោសខ្លួនឯង បណ្ដាលមកពីអារម្មណ៍ដែលខ្លួនឯងទទួលខុសត្រូវចំពោះការឆ្គាំឆ្គង ឬអំពើល្មើស ។ ការពិតឬសភាពដែលបានធ្វើខុស ឬបានប្រព្រឹត្តបទល្មើស ។ |
| Hallucination<br>ការស្រមើស្រមៃ | False or distorted perception of object or events with compelling sense of their reality, usually resulting from a mental disorder or drug | គំនិតមិនពិតទៅលើវត្ថុ ឬព្រឹត្តិការណ៍ ដែលជម្រុញឲ្យមានអារម្មណ៍ថាជាការពិត។ ជាធម្មតា បណ្ដាលមកពីវិបត្តិផ្លូវចិត្ត ឬការប្រើគ្រឿងញៀន។ |
| Harmony (in family)<br>ភាពសុខដុម (ក្នុងគ្រួសារ) | Agreement in action, opinion, feeling; order or congruity of parts to their whole or to one another | ការឯកភាពគ្នាចំពោះសកម្មភាព គំនិត អារម្មណ៍ លំដាប់លំដោយ ឬភាពត្រូវ គ្នានៃផ្នែកមួយចំនួនទៅនឹងរបស់ទាំងមូល ឬទៅនឹងផ្នែកផ្សេងទៀត។ |
| Headache<br>ឈឺក្បាល | A pain located in the head, as over the eyes, at the temples, or at the base of the skull | ការឈឺចាប់នៅក្នុងក្បាល ដូចជា នៅភ្នែក នៅសៀតផ្កា ឬនៅលលាក្បាល |
| Hope<br>សង្ឃឹម | To believe, desire, or trust; to feel that something desired may happen | ជឿ ត្រូវការ ទុកចិត្ត មានអារម្មណ៍ថាអ្វីមួយដែលចង់បានអាចកើតឡើង។ |
| Hopelessness<br>សេចក្ដីអស់សង្ឃឹម | A feeling of futility and passive abandonment of oneself to fate | អារម្មណ៍អស់សង្ឃឹម និងការបោះបង់ខ្លួនឯងចោលទៅតាមព្រហ្មលិខិត។ |
| Karma<br>កម្ម | Fate; destiny | ព្រហ្មលិខិត ជោគវាសនា។ |
| Happy<br>រីករាយ | Delighted, pleased, or glad, as over a particular thing; Feeling, showing or expressing joy | រីករាយខ្លាំង សប្បាយចិត្ត ដោយសាររបស់ពិសេសអ្វីមួយ ការបង្ហាញអារម្មណ៍រីករាយ។ |

| Term | English Definition | Khmer Translation/Description |
|---|---|---|
| Loneliness<br>ភាពឯកការ | Resulting from the state of being alone; isolated, unfrequented, or desolate | បណ្ដាលមកពីសភាពនៅម្នាក់ឯង ត្រូវគេបោះបង់ចោល ឬសោះកក្រោះ។ |
| Meditation<br>ការភាវនា | Continued or extended thought; reflection; contemplation; devout religious contemplation or spiritual introspection | ការបន្ត ឬពង្រីកនូវគំនិត ។ ការឆ្លុះបញ្ចាំង ការសញ្ជឹងគិត ។ ការគិតគូរអំពីសាសនា ឬការគិតពីស្មារតីរបស់ខ្លួនឯង ។ |
| Memory<br>ការចងចាំ | A mental impression retained; a recollection | ចំណាប់អារម្មណ៍ខួរក្បាលដែលបានរក្សាទុក ។ ការនឹកឃើញ ។ |
| Mental health<br>សុខភាពផ្លូវចិត្ត | Psychological well-being and satisfactory adjustment to society and to the ordinary demands of life | សុខមាលភាពផ្លូវចិត្ត និងការសំរបខ្លួនដោយពេញចិត្តទៅនឹងសង្គម និង តម្រូវការធម្មតារបស់ជីវិត។ |
| Mental health professional<br>គ្រូពេទ្យសុខភាពផ្លូវចិត្ត | A health care practitioner who offers services for the purpose of improving an individual's mental health or to treat mental illness. | គ្រូពេទ្យសុខភាពដែលផ្ដល់សេវាកម្ម ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវសុខភាពផ្លូវចិត្តរបស់មនុស្ស ឬព្យាបាលជម្ងឺផ្លូវចិត្តមនុស្ស។ |
| Mental illness<br>ជម្ងឺផ្លូវចិត្ត | Any of various disorders in which a person's thoughts, emotions, or behavior are so abnormal as to cause suffering to himself, herself, or other people | វិបត្តិផ្សេងៗណាមួយដែលគំនិត អារម្មណ៍ ឬអាកប្បកិរិយារបស់មនុស្សមានភាពមិនប្រក្រតីដែលបណ្ដាលឲ្យមានការឈឺចាប់ចំពោះខ្លួនឯង ឬអ្នកដទៃ។ |
| Nervousness<br>ភាពភ័យបារម្ភ | Highly excitable; unnaturally or acutely uneasy or apprehensive | ដែលភ្ញាក់ផ្អើលខ្លាំង ។ ដែលមិនស្រណុក ឬព្រួយបារម្ភខ្លាំងខុសធម្មតា |
| Nightmare<br>សុបិន្តអាក្រក់ | A terrifying dream in which the dreamer experiences feelings of helplessness, extreme anxiety, sorrow, etc. | ការយល់សប្តិគួរឲ្យខ្លាច ដែលអ្នកយល់សប្តិមានអារម្មណ៍គ្មានជំនួយ ព្រួយបារម្ភយ៉ាងខ្លាំង កើតទុក្ខ ។ល។ |
| Obsessive Compulsive Disorder<br>ជម្ងឺរវើរវាយខ្លាំង | A disorder in which individuals are plagued by persistent, recurring thoughts or obsessions that reflect exaggerated anxiety or fears. | ជាវិបត្តិមួយដែលបុគ្គលត្រូវញាំញីដោយគំនិត ឬការស្រមើស្រម៉ៃកើតមានជារឿយៗ ដែលឆ្លុះបញ្ចាំងអំពីការព្រួយបារម្ភ ឬការភ័យខ្លាចលើសពីការពិត ។ |
| Optimism<br>សុទិដ្ឋិនិយម | The belief that good ultimately predominates over evil in the world | ជំនឿដែលអំពើល្អគ្របដណ្ដប់លើអំពើអាក្រក់ជារៀងរហូតនៅក្នុងពិភពលោក។ |
| Over eating and weight gain<br>ការញុំាលើសកំណត់ និងការឡើងទម្ងន់ | To eat more than is good for oneself | ញុំាច្រើនលើសធម្មតា។ |

| Term | English Definition | Khmer Translation/Description |
| --- | --- | --- |
| Pain<br>ការឈឺចាប់ | A physical suffering or distress, as due to injury, illness, etc. | ការឈឺចាប់ផ្នែករាងកាយ ឬការកើតទុក្ខ ដោយសារការរបួស ជម្ងឺ ។ល។ |
| Panic attack<br>ឆាប់ភ័យរន្ធត់ | An intense attack of anxiety characterized by feelings of impending doom and trembling, sweating, pounding heart, and other physical symptoms | ការឆាប់ព្រួយបារម្ភខ្លាំងដែលកើតឡើងតាមរយៈអារម្មណ៍ថាសេចក្តីស្លាប់ជិតមកដល់ និងមានអារម្មណ៍ញ័រ បែកញើស បេះដូងលោតខ្លាំង និងរោគសញ្ញាផ្នែករាងកាយដទៃទៀត។ |
| Personality disorder<br>វិបត្តិបុគ្គលិកលក្ខណៈ | Any of a group of mental disorders characterized by deeply ingrained maladaptive patterns of behavior and personality style, which are usually recognizable as early as adolescence and are often lifelong duration | ក្រុមនៃវិបត្តិផ្លូវចិត្តណាមួយដែលកំណត់ដោយគំរូអាកប្បកិរិយាមិនអាចប្រែប្រួលបាន និងកប់ណែនយ៉ាងជ្រៅ និងរចនាបថបុគ្គលិកលក្ខណៈ ដែលជាធម្មតាត្រូវបានស្គាល់តាំងពីវ័យក្មេងនិងជារឿយៗមានរយៈពេលមួយជីវិត។ |
| Post-traumatic stress<br>ជម្ងឺតានតឹងអារម្មណ៍ក្រោយពេលមានរបួស | Caused by the experience of a wide range of traumatic events and, particularly if the trauma is extreme, can occur in persons with no predisposing conditions | បណ្តាលដោយសារបទពិសោធន៍ធ្លាប់ជួបព្រឹត្តិការណ៍របួស និង ជាពិសេសប្រសិនបើរបួសធ្ងន់ធ្ងរ នោះអាចកើតឡើងដោយផ្ទាល់ដោយមិនមានការគ្រោងទុកជាមុន។ |
| Prevention<br>ការបង្ការ | The act of prevention; a hindrance, obstacle or impediment | អំពើនៃការទប់ស្កាត់ រាំងស្ទះ បង្កជាឧបសគ្គ ឬការបង្អាក់។ |
| Psychiatrist<br>គ្រូពេទ្យវិកលចរិក | A physician who specializes in the diagnosis and treatment of mental disorders | គ្រូពេទ្យដែលមានជំនាញខាងការវិភាគរោគ និងព្យាបាលវិបត្តិផ្លូវចិត្ត |
| Relax<br>បន្ធូរអារម្មណ៍ | To release or bring relief from the effects of tension, anxiety, etc. | ជម្រុះចោល ឬនាំឲ្យមានការធូរស្បើយ ពីឥទ្ធិពលនៃភាពតានតឹងក្តីកង្វល់ ។ល។ |
| Rest<br>សម្រាក | A period or interval of inactivity, repose, solitude, or tranquility; mental or spiritual calm | រយៈពេល ឬចន្លោះពេលនៃគ្មានសកម្មភាព ភាពស្ងប់ស្ងាត់ នៅម្នាក់ឯង ឬភាពសុខសាន្ត  ភាពស្ងប់ក្នុងផ្លូវចិត្ត ឬស្មារតី ។ |
| Sadness<br>ការពិបាកចិត្ត | Causing sorrow; affected by unhappiness or grief; sorrowful or mournful | បណ្តាលមកពីការព្រួយបារម្ភ ជះឥទ្ធិពលដោយសារអពមង្គល ឬទុក្ខព្រួយ  ឬការសោកសង្រេង។ |
| Shame<br>ភាពខ្មាស់អៀន | A fact or circumstance bringing disgrace or regret | ការពិត ឬកាលៈទេសៈដែលនាំឲ្យមានការអាម៉ាស់ ឬការសោកស្តាយ។ |
| Side effects<br>ការជះឥទ្ធិពលត្រលប់ | Any effect of a drug, chemical, or other medicine that is in addition to its intended effect, especially an effect that is harmful or unpleasant | ឥទ្ធិពលណាមួយនៃថ្នាំញៀន ថ្នាំគីមី ឬថ្នាំផ្សេងទៀតដែលលើសពីឥទ្ធិពលបានកំណត់របស់ខ្លួន ជាពិសេសឥទ្ធិពលដែលមានផលអាក្រក់ ឬផលមិនល្អ។ |

| Term | English Definition | Khmer Translation/Description |
| --- | --- | --- |
| Spirit<br>ស្មារតី | The principle of conscious life; the vital principle in humans, animating the body or mediating between body and soul | គោលការណ៍នៃជីវិតដែលមានមនៈសិការ ។ គោលការណ៍សំខាន់ចំពោះមនុស្ស ដែលធ្វើឲ្យរាងកាយមានជីវិត ឬសម្របសម្រួលរវាងរាងកាយ និងព្រលឹង។ |
| Stigma<br>ស្លាកស្នាមទុរយស | A mark of disgrace of infamy; a stain or reproach, as to one's reputation | សញ្ញានៃភាពទុរយស  ការប្រទ្បាក់ប្រទ្បូស ឬការស្តីបន្ទោសចំពោះកេរ្តិ៍ឈ្មោះរបស់នរណាម្នាក់។ |
| Stress<br>ជម្ងឺតានតឹងអារម្មណ៍ | Mental, emotional, or physical strain or tension | សម្ពាធ ឬភាពតានតឹងផ្លូវចិត្ត អារម្មណ៍ ឬរាងកាយ |
| Struggle<br>តស៊ូ | To contend with an adversary or opposing force | តស៊ូប្រយុទ្ធនឹងកម្លាំងសត្រូវ ឬប្រឆាំង |
| Suicide<br>អត្តឃាត | The intentional taking of one's own life | ការសម្លាប់ជីវិតរបស់ខ្លួនឯងដោយខ្លួនឯងដោយចេតនា។ |
| Survivor<br>អ្នកគេចផុតពីអ្វីមួយ | A person who continues to function or prosper in spite of opposition, hardship, or setbacks | មនុស្សដែលបន្តសកម្មភាព ឬបន្តឲ្យចម្រើនរុងរឿង ទោះបីជាមានការប្រឆាំង ការលំបាក ឬការបរាជ័យ។ |
| Traumatized<br>មានរបួស | To cause a trauma in the mind | បណ្តាលឲ្យមានរបួសផ្លូវចិត្ត។ |
| Trembling<br>ញ័ររន្ធត់ | To shake involuntarily with quick, short movements, as from fear, excitement, weakness or cold; quake; quiver; to be troubled with fear or apprehension | ញ័រដោយអចេតនា ជាមួយចលនាខ្លី និងលឿន មកពីការភ័យ ការរំភើប ខ្សោយ ឬរងារ ញ័ររញ្ជួយ ។ មានបញ្ហាជាមួយនឹងការភ័យខ្លាច ឬការព្រួយបារម្ភ។ |
| Unstable<br>មិននឹងនរ | Emotional instability | មានអារម្មណ៍មិននឹងនរ។ |
| Wellness<br>សុខភាពល្អ | The quality or state of being healthy in body and mind, especially as the result of deliberate effort | លក្ខណៈសម្បត្តិ ឬសភាពនៃសុខភាពល្អនៅក្នុងរាងកាយ និងចិត្ត ជាពិសេស ជាលទ្ធផលនៃការខិតខំប្រឹងប្រែងដែលមានការគិតទុកជាមុន |

Funded by the voter approved Mental Health Services Act (Prop. 63).